**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីប្រកាសព័ត៌មាន

# ស្តីពី

# ការឈប់ទទួលស្គាល់វិទ្យាស្ថានអ៊ិកសែលប៉ូលីធាន

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនសាធារណជន សិក្ខាកាម សិស្ស និស្សិត មេត្តាជ្រាបថា ក្រសួងបានសម្រេចឈប់ទទួលស្គាល់ **វិទ្យាស្ថានអ៊ិកសែលប៉ូលីធាន** សរសេរកាត់ថា **"វ.អ.ប"** ជាភាសាអង់គ្លេស "EXCELPOLITAN INSTITUTE" សរសេរកាត់ថា "E.P.I" មានទីតាំងនៅអគារ SUNTOWN PLAZA ស្ថិតនៅមហាវិថីសហព័ន្ធរុស្ស៊ី កែងផ្លូវ NORTHBRIDGE សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ ដោយវិទ្យាស្ថាននេះមិនបានអនុវត្តតាមស្មារតីប្រកាសដែលក្រសួងអនុញ្ញាតឲ្យធ្វើការបណ្តុះបណ្តាល។ គិតត្រឹមថ្ងៃនេះ វិទ្យាស្ថានមិនទាន់បានធ្វើការបណ្តុះបណ្តាលនៅឡើយទេ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសាធារណជន សិក្ខាកាម សិស្ស និស្សិត មេត្តាជ្រាបជាព័ត៌មានតាមការគួរ។

ថ្ងៃអង្គារ ១២កើត ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៩

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩